ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណាននីង

លេខ ០០៦៧ កពណក.ណន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u> : របាយការណ៍ប្រចាំខែមិថុនា ឆ្នាំ២០១១**

ខ្ញុំបាទមានកិត្តិយសគោរពជូន ឯកឧត្តម **ទេសរដ្ឋមន្ត្រី** នូវរបាយការណ៍ប្រចាំខែមិថុនា ឆ្នាំ២០១១ ដូចខាងក្រោម :

**១ <u>ការងារទំនាក់ទំនងផ្សេងៗ :</u>**

- ទស្សនកិច្ចកសិដ្ឋានដាំបន្លែ Zhongcai Shunming Agriculture Technology Co.,Ltd និង កសិដ្ឋាន Huangshi Daily កសិដ្ឋានទាំង២នេះមានបំណងវិនិយោគទុននៅកម្ពុជា ក្នុងការដាំដុះដំណាំតាមបច្ចេកទេសខ្ពស់ ។

- ចូលរួមសន្និសីទសារពត៌មាននៃការតាំងពិព័រណ៍ Yuan Ming Yuan នៅGuangxi Great Hall ។

- ជួបសំដែងការគួរសមនៅមន្ទីរកសិកម្ម មន្ទីរទេសចរណ៍ខេត្តក្វាងស៊ី និងមន្ទីរទេសចរណ៍ក្រុងណាននីង ។

- ជួបពិភាក្សាជាមួយមន្ត្រីការិយាល័យជំរុញវិនិយោគនៅក្រុងណាននីង ដែលគេមានបំណងសហការជាមួយកម្ពុជា ក្នុងការផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគ ហើយគេមានគំរោងទៅទស្សនកិច្ចនៅកម្ពុជា ដើម្បីសំដែងការគួរសមជាមួយឯកឧត្តម **ទេសរដ្ឋមន្ត្រី** និងគ្រោងបើកសិក្ខាសាលា ដោយអញ្ជើញពាណិជ្ជករកម្ពុជាចូលរួម ។

- ជួប Guangxi International Exposition Bureau ដើម្បីសហការរៀបចំពិព័រណ៍ចិន-អាស៊ាន ឱ្យកាន់តែប្រសើរឡើង ។

- ជួបក្រុមហ៊ុន China south City មានបំណងសាងសង់ផ្សារលក់ទំនិញអាស៊ាន ដោយលើកទឹកចិត្តមិនយកថ្លៃជួលស្តង់លក់ដូររយៈពេល៥ឆ្នាំដំបូងពីពាណិជ្ជករកម្ពុជា។

- ចូលរួមពិធីបើកសម្ពោធពិព័រណ៍ " Thai Shopping Festival 2011" នៅ China Resource Vanguard ។

**សភាពការណ៍សេដ្ឋកិច្ចនៅតំបន់ខេត្តក្វាងស៊ី**

ខេត្តក្វាងស៊ីជាខេត្តសម្ពន្ធភាពជាមួយកម្ពុជា លើការងារសហប្រតិបត្តិការ សេដ្ឋកិច្ច-ពាណិជ្ជកម្មទ្វេភាគី ។ ខេត្តក្វាងស៊ីមានការអភិវឌ្ឍន៍ខ្ពស់ មានបំណងបន្ថែមកិច្ចសហការយ៉ាងស្អិតរមួតជាមួយកម្ពុជា ដោយភាគីកម្ពុជាមានឧត្តមភាពផ្នែកធនធានធម្មជាតិ ឯភាគីចិនមានសក្តានុពលផ្នែកឧស្សាហកម្មទំនើប ។ ទៅអនាគត ដើម្បីសំរេច គោលបំណងឈ្នះ-ឈ្នះ ភាគីចិនមានបំណងសហការជាមួយកម្ពុជា ដែលមានទិសដៅដូចតទៅ :

-១ បន្ថែមកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគទ្វេភាគី ។ ស្រាវជ្រាវនិងជំរុញកិច្ចសហការរវាងរដ្ឋាភិបាល និងសហគ្រាសលើវិស័យពាណិជ្ជកម្មនិងវិនិយោគ និងបន្ថែមការផ្លាស់ប្តូរពតិមានគ្នាទៅវិញទៅមក ។ ពង្រីកទំនាក់ទំនងវិស័យបច្ចេកទេសផលិតផល និង ការគ្រប់គ្រង ។ លើកទឹកចិត្តសហគ្រាសឱ្យចូលរួមធ្វើអាជីវកម្ម កសិកម្ម រ៉ែ និងធារាសាស្ត្រ ។

-២ ពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មនិងឧស្សាហកម្ម ។ ជាក់ស្តែង ខេត្តក្វាងស៊ីលើកទឹកចិត្តសហគ្រាសផលិតនិងកែច្នៃគ្រឿងយន្តកសិកម្ម គួបផ្សំជាមួយធនធានកសិកម្មកម្ពុជា និងបច្ចេកទេសដាំដុះលើវិស័យកសិកម្មរបស់ភាគីចិន ។

-៣ ពង្រីកកិច្ចសហប្រតិបត្តិការលើផ្នែកឧស្សាហកម្ម ។ ជំរុញនិងសហការគ្នាលើវិស័យវារីអគ្គីសនី និងការកែច្នៃអង្ករឱ្យមានគុណភាពខ្ពស់របស់កម្ពុជា បំរើឱ្យការនាំចេញទៅលើទីផ្សារអន្តរជាតិ ។

-៤ ពង្រីកសហប្រតិបត្តិការលើវិស័យទេសចរណ៍និងសហការជាមួយគ្នាក្នុងការរៀបចំពិព័រណ៍ចិន-អាស៊ានឱ្យបានល្អ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយអនុគ្រោះបំផុត ។

សូម ឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ក្រុងណាននីង ថ្ងៃទី / ខែកក្កដា ឆ្នាំ២០១១

ទីប្រឹក្សាពាណិជ្ជកម្ម

**អ៊ុច គឹមយ៉ិន**

ចម្លងជូន

- អគ្គកុងស៊ុលប្រចាំក្រុងណាននីង
- ឯកសារនិងកាលប្បវត្តិ

Add : #11Zhujin Road,China-ASEAN Business District,Nanning, Guangxi ,China Email: clo_cambodia@yahoo.com Tel/Fax: (0771)5389496